**មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)**

ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦

# អត្ថបទផ្សព្វផ្សាយព័ត៌មានរបស់អង្គការ សេដាក

*ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១១*

## កិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមកសិករផលិតបន្លែសរីរាង្គ

តំណាងក្រុមកសិករអ្នកផលិតបន្លែសរីរាង្គចំនួន ៤០ នាក់ មកចូលរួមការប្រជុំប្រចាំឆ្នាំ ដែលមានរយៈពេលពីរថ្ងៃ ពីថ្ងៃទី ១៥-១៦ ខែធ្នូ ឆ្នាំ ២០១១ នៅការិយាល័យអង្គការ សេដាក ក្រុងភ្នំពេញ។

អង្គការសេដាក បាននិងកំពុងធ្វើការជម្រុញការផលិត និងដាំដុះបន្លែតាមគោលការណ៍ធម្មជាតិទៅដល់គ្រួសារកសិករប្រមាណជាង ១៤ ម៉ឺនគ្រួសារនៅទូទាំងភូមិឃុំ ដែលជាតំបន់គោលដៅរបស់ខ្លួននៅក្នុង ២២ ខេត្តក្រុង។ ក្នុងចំណោមកសិករដែលសហការទាំងអស់ អង្គការសេដាក បានជ្រើសរើសក្រុមកសិករដើម្បីចូលរួមគំរោងសាកល្បងក្នុងការដាំបន្លែសរីរាង្គមកកាន់ទីផ្សារ។ មកដល់ពេលបច្ចុប្បន្ន ក្នុងក្របខ័ណ្ឌគំរោងសាកល្បង អង្គការសេដាក បានរៀបចំចងក្រងក្រុមកសិករអ្នកផលិត បន្លែបានចំនួន ៧០ នាក់នៅក្នុងខេត្តចំនួន ៥ រួមមានខេត្តកំពត កំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល និងខេត្តតាកែវ ដែលអាចផលិតបន្លែបានចំនួនប្រមាណ ២០០ គីឡូក្រាមក្នុងមួយថ្ងៃ ផ្គត់ផ្គង់ជាប្រចាំមកកាន់ទីផ្សារក្នុងទីក្រុងភ្នំពេញ។ លើសពីនេះ សេដាក ក៏បានបង្កើតកសិដ្ឋានសរីរាង្គបានចំនួន ៣ កន្លែងសំរាប់ជាការបង្ហាញ និងបណ្តុះបណ្តាលពីការធ្វើកសិកម្មសរីរាង្គ ក៏ដូចជាដើម្បីបំពេញនូវតំរូវការរបស់ទីផ្សារពេលបច្ចុប្បន្ន។

លោក លឹម សុគុន្ធដារុណ អ្នកសម្របសម្រួលកម្មវិធីជំនួញសហគមន៍អង្គការសេដាក មានប្រសាសន៍ថា " នៅក្នុងអំឡុងពេលកិច្ចប្រជុំរយៈពេលពីរថ្ងៃនេះ ក្រុមកសិករផលិតបន្លែសរីរាង្គនឹងធ្វើការរៀនសូត្របន្ថែមអំពីព័ត៌មាន ស្តីពីឱកាស និងការប្រឈម ដើម្បីក្លាយជាអ្នកផលិតបន្លែសរីរាង្គអាជីព និងដើម្បីបង្កើនការផលិតបន្លែសរីរាង្គសំរាប់ លក់ទៅទីផ្សារ"។ លោកបន្តថា " ក្រុមកសិករក៏នឹងធ្វើការសិក្សាអំពីថម្លៃទីផ្សារ និងសក្តានុពលបន្លែសរីរាង្គនៅលើ ទីផ្សារតាមរយៈការចុះទៅទស្សនាផ្ទាល់នៅតាមផ្សារមួយចំនួនដូចជា ផ្សារដើមគរ ផ្សារទំនើប និងផ្សារសេដាក។

អ្នកស្រីទីវ ឆាត ជាកសិករនៅភូមិថ្នាប ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងមានប្រសាសន៍ថា *"បន្ទាប់ពីបានចាប់យកអាជីពជាអ្នកផលិតបន្លែសរីរាង្គ ជីវភាពរបស់គ្រួសារគាត់មានភាពធូរធារច្រើន ដោយគាត់អាចរកប្រាក់ចំណូលពីការដាំបន្លែនៅលើដីទំហំ ៧ អាររបស់គាត់បានជាមធ្យម ១ លានរៀលក្នុងមួយខែ"*។ អ្នកស្រីបន្តថា *"ក្រៅពីប្រាក់ចំណូល ដែលទទួលបានជាប្រចាំពីការដាំបន្លែរបស់គាត់ ដែលមានស្ទើរតែគ្រប់មុខដូចជា ស្ពៃ សាឡាត់ ស្ពៃខ្មៅ ស្ពៃជើងទា ម្រះព្រៅ ជីគ្រប់មុខ ត្រកួន ននោង និងបន្លែផ្សេងៗទៀតនោះ សុខភាពរបស់សមាជិកគ្រួសារគាត់ក៏មានភាពប្រសើរច្រើនផងដែរ តាមរយៈការទទួលទាននូវបន្លែសរីរាង្គប្រចាំថ្ងៃ"*។

ប្រធានអង្គការសេដាក លោកបណ្ឌិត យ៉ង សាំងកុមារ មានប្រសាសន៍បញ្ជាក់ថា ឈរលើបទពិសោធន៍ ដែលទទួលបានតាមរយៈការអនុវត្តគំរោងសាកល្បងការគាំទ្រការផលិតបន្លែសរីរាង្គ អង្គការសេដាក នឹងពង្រីងពង្រីកការ

ដាំបន្លែសរីរាង្គបន្ថែមទៀត ដើម្បីឱ្យកសិករច្រើននាក់ទៀតអាចទទួលបាននូវប្រាក់ចំណូលច្រើន ពីអាជីពដាំបន្លែសរីរាង្គ ហើយអ្នកបរិភោគអាចទទួលបាននូវបន្លែប្រកបដោយសុវត្ថិភាពទទួលទាន។

បច្ចុប្បន្ន តម្រូវការបន្លែមានកាន់តែច្រើនឡើង ជាពិសេសបន្លែសរីរាង្គ ប៉ុន្តែបន្លែប្រមាណ ៤០-៦០% ត្រូវបាននាំចូលពីប្រទេសជិតខាង។ ដូចនេះ អាជីពផលិតបន្លែសំរាប់ផ្គត់ផ្គង់មកទីផ្សារពិតជាមានសក្តានុពលខ្ពស់។

អង្គការសេដាក សូមអំពាវនាវឱ្យកសិករខ្មែរ ងាកមកចាប់អាជីពជាអ្នកផលិតបន្លែឱ្យបានច្រើន ជាពិសេសបន្លែសរីរាង្គ។ ចាប់ពីឆ្នាំ ២០១២ ទៅអង្គការសេដាក នឹងពង្រីកការគាំទ្រលើការផលិតបន្លែសរីរាង្គ និងទីផ្សារបន្លែសរីរាង្គឱ្យបានទូទាំងប្រទេស។

**ទំនាក់ទំនង:** សម្រាប់ព័តិមានបន្ថែម សូមទំនាក់ទំនងលោក ហ៊ឹម ខទៀត: ០១៦ ៥៧ ៥៧ ១៣

**Centre d’Etude et de Développement Agricole Cambodgien (CEDAC)**

No 119 St. 257 Sangkat Teuk Laak 1, Khan Toul Kork, Phnom Penh - Cambodia
P.O.Box: 118, Tel.: 855-23-880 916, Fax: 855-23-885-146, E-mail: cedacinfo@cedac.org.kh